ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



# គោលការណ៍ណែនាំជាតិ ស្តីពីការធ្វើរោគវិនិច្ឆ័យ និងព្យាបាល ការពុលសារធាតុមេតាណុល ក្នុងប្រទេសកម្ពុជា

រៀបចំឡើងដោយ

នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង

សហការជាមួយ

អង្គការសុខភាពពិភពលោក

អង្គការគ្រូពេទ្យគ្មានព្រំដែន

មន្ទីរពេទ្យសកលវិទ្យាល័យអូស្លូ (OUH)

គម្រោងស្តីពីការពុលមេតាណុល (MPi)

# អារម្ភកថា

គោលការណ៍ណែនាំជាតិ ស្តីពីការធ្វើរោគវិនិច្ឆ័យ និងព្យាបាលការពុលសារធាតុមេតាណុលក្នុងប្រទេសកម្ពុជា ត្រូវបានរៀបចំឡើងក្រោមកិច្ចសហការរវាង នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង នៃក្រសួងសុខាភិបាលកម្ពុជា មន្ទីរពេទ្យកាល់ម៉ែត មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិន ព្រះកុសមៈ មន្ទីរពេទ្យខេត្តក្រចេះ មន្ទីរពេទ្យខេត្តកំពង់ឆ្នាំង មន្ទីរពេទ្យខេត្តកំពង់ចាម អង្គការគ្រូពេទ្យគ្មានព្រំដែន អង្គការសុខភាពពិភពលោក មន្ទីរពេទ្យសាកលវិទ្យាល័យអូស្លូ និងគម្រោងស្តីពីការពុលមេតាណុល ។

ការពុលមេតាណុល គឺជាការគំរាមកំហែងមួយចំពោះសុខភាព ដោយសម្លាប់មនុស្សរាប់ពាន់នាក់នៅទូទាំងពិភពលោក ក៏ដូចជាធ្វើឱ្យពិការភ្នែក ឬខូចខួរក្បាលជាអចិន្ត្រៃយ៍។ សារធាតុពុលនេះកើតមានឡើងជាប្រចាំនៅក្នុងប្រទេសកម្ពុជាផងដែរ ហើយបញ្ហាមិនត្រឹមតែប៉ះពាល់ដល់អ្នកជំងឺប៉ុណ្ណោះទេ ប៉ុន្តែក៏ប៉ះពាល់ដល់គ្រួសាររបស់ពួកគេ និងសង្គមទាំងមូលផងដែរ ព្រោះថាជារឿយៗអ្នករកប្រាក់ចំណូលចិញ្ចឹមគ្រួសារគឺជាអ្នកដែលត្រូវស្លាប់ ឬពិការ ។ ជាធម្មតាការធ្វើរោគវិនិច្ឆ័យ គឺមានការពិបាក ហើយអ្នកជំងឺអាចត្រូវបានគេមើលរំលងដោយងាយ។ ផ្អែកលើការព្រួយបារម្ភទាំងនេះ អ្នកជំនាញមួយក្រុមត្រូវបានបង្កើតឡើង ដើម្បីរៀបចំបង្កើតគោលការណ៍ណែនាំជាលក្ខណៈប្រព័ន្ធ តាមបែបវិទ្យាសាស្ត្រ ដែលអាចត្រូវបានយកទៅអនុវត្តនៅក្នុងតំបន់ដែលមានមធ្យោបាយធ្វើរោគវិនិច្ឆ័យ និង ព្យាបាលតិចតួច។

ខ្ញុំមានសេចក្តីរីករាយដោយឃើញការងារថ្មីនេះកំពុងតែកើតឡើង នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលខ្ញុំសង្ឃឹមថា អាចក្លាយជាគំរូមួយសម្រាប់ប្រទេសដទៃទៀតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ទោះបីយ៉ាងណាក៏ដោយ វាជាការសំខាន់ដែលត្រូវទទួលស្គាល់ថា ការងារមិនទាន់ចប់ត្រឹមការអភិវឌ្ឍន៍គោលការណ៍ណែនាំនេះទេ។ ឥឡូវនេះគឺដល់ពេលដែលត្រូវអនុវត្តចំណេះដឹងនេះទៅក្នុងការអនុវត្តន៍ប្រចាំថ្ងៃ។

ខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមការងាររបស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង មន្ទីរពេទ្យជាតិ និង មន្ទីរពេទ្យខេត្តនៃប្រទេសកម្ពុជា ដែលបានមើលឃើញពីភាពចាំបាច់នៃការបង្កើតគោលការណ៍ណែនាំនេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរដល់គម្រោងស្តីពីការពុលមេតាណុល និង មន្ទីរពេទ្យនៃសាកលវិទ្យាល័យអូស្លូ អង្គការសុខភាពពិភពលោក អង្គការគ្រូពេទ្យគ្មានព្រំដែន ដែលមានតួនាទីសម្របសម្រួល និងបាននាំមកនូវជំនាញនាំមុខគេនៅក្នុងពិភពលោក ហើយបានប្រមូលផ្តុំដាក់បញ្ចូលគំនិតទាំងនេះរួមគ្នា។

ខ្ញុំសង្ឃឹមថាគោលការណ៍ណែនាំនេះ រួមជាមួយការផ្តល់ការបណ្តុះបណ្តាល និងការប្រាស្រ័យទាក់ទងហានិភ័យ នឹងជួយសង្គ្រោះអាយុជីវិត និងសុខភាពដែលផ្តល់អត្ថប្រយោជន៍ដល់អ្នកជំងឺ និងក្រុមគ្រួសាររបស់ពួកគេនៅក្នុងបណ្តាឆ្នាំខាងមុខ។

រដ្ឋលេខាធិការ

សាស្ត្រាចារ្យ អេង_ហួត

# បញ្ជីឈ្មោះអ្នកចូលរួម

| ឈ្មោះ | តួនាទី នឹង ស្ថាប័ន |
|---|---|
| លោកវេជ្ជ. លី សូវ៉ាន់ | ប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| លោកស្រីវេជ្ជ. តេង ស្រី | អនុប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| លោកវេជ្ជ. ចាន់ វុទ្ធី | អនុប្រធានការិ.តាមដាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| លោកវេជ្ជ. ប៉ែន វង្ឃា | អនុប្រធានការិ.តាមដាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| លោកវេជ្ជ. កែវ សំឡី | មន្ត្រីជាន់ខ្ពស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| លោកវេជ្ជ. ម៉ូវ ឆ័យយុត្តិ | មន្ត្រីជាន់ខ្ពស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| កញ្ញា ហ៊ិត ឈុនអ៊ី | មន្ត្រីជាន់ខ្ពស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| លោកឱសថការី សី យុគីវ | អនុប្រធានការិ.សថសារវ័ត្ត នៃនាយកដ្ឋានឧសថ, ចំណីអាហារ នឹងគ្រឿងសំអាង |
| លោក ហាប់ សិលាវុធ | មន្ត្រីជាន់ខ្ពស់នាយកដ្ឋានឧសថ, ចំណីអាហារ នឹងគ្រឿងសំអាង |
| សាស្ត្រាចារ្យ ឈួយ ម៉េង | ប្រធានផ្នែកប្រពោធនកម្ម មន្ទីរពេទ្យកាល់ម៉ែត |
| សាស្ត្រាចារ្យ ឈរ ណារ៉េត | ប្រធានផ្នែកសង្គ្រោះបន្ទាន់ មន្ទីរពេទ្យកាល់ម៉ែត |
| សាស្ត្រាចារ្យ តាំង សុវណ្ណា | ផ្នែកសង្គ្រោះបន្ទាន់ មន្ទីរពេទ្យកាល់ម៉ែត |
| លោកវេជ្ជ. យឹម វឌ្ឍនះ | ផ្នែកសង្គ្រោះបន្ទាន់ មន្ទីរពេទ្យកាល់ម៉ែត |
| លោកវេជ្ជ. សួន សាមិត្ត | ប្រធានផ្នែកសង្គ្រោះបន្ទាន់ មន្ទីរពេទ្យមិត្តភាព ខ្មែរ សូវៀត |
| លោកវេជ្ជ. ទេស សុវណ្ណារ៉ា | ផ្នែកសង្គ្រោះបន្ទាន់ មន្ទីរពេទ្យមិត្តភាព ខ្មែរ សូវៀត |
| លោកវេជ្ជ. ភាវ ផាន់ណារ័ត្ន | ផ្នែកជំងឺទូទៅ មន្ទីរពេទ្យមិត្តភាព កម្ពុជា ចិន ព្រះកុសុមះ |
| លោកវេជ្ជ. ទុំ សក្កានុពល | ផ្នែកជំងឺទូទៅ មន្ទីរពេទ្យមិត្តភាព កម្ពុជា ចិន ព្រះកុសុមះ |
| លោកវេជ្ជ. លី ធារុធ | ប្រធានផ្នែកសង្គ្រោះបន្ទាន់ មន្ទីរពេទ្យខេត្តក្រចេះ |
| លោកវេជ្ជ. ណី វណ្ណារ៉ា | ប្រធានផ្នែកជំងឺទូទៅ មន្ទីរពេទ្យខេត្តក្រចេះ |
| លោកវេជ្ជ. សុខ ច័ន្ទតារា | ផ្នែកសង្គ្រោះបន្ទាន់ មន្ទីរពេទ្យខេត្តកំពង់ចាម |
| លោកស្រីវេជ្ជ. ហេង សូរិយា | ផ្នែកសង្គ្រោះបន្ទាន់ មន្ទីរពេទ្យខេត្តកំពង់ចាម |
| លោកវេជ្ជ. ហ៊ាង លឹមហុង | ផ្នែកវះកាត់ មន្ទីរពេទ្យខេត្តកំពង់ចាម |
| លោកវេជ្ជ. ម៉ុត ដារ៉ាវុធ | ផ្នែកជំងឺទូទៅ មន្ទីរពេទ្យខេត្តកំពង់ឆ្នាំង |
| លោកវេជ្ជ. ទត ធារ៉ា | ផ្នែកសង្គ្រោះបន្ទាន់ មន្ទីរពេទ្យខេត្តកំពង់ឆ្នាំង |
| លោក. ឈុន មករា | ក្រុមឆ្លើតបបន្ទាន់ មន្ទីរសុខាភិបាលខេត្តក្រចេះ |
| លោកស្រី. វ៉ា វណ្ណា | ក្រុមឆ្លើតបបន្ទាន់ មន្ទីរសុខាភិបាលខេត្ត កំពង់ចាម |
| លោកស្រី. ប៉ាន មករា | ក្រុមឆ្លើតបបន្ទាន់ មន្ទីរសុខាភិបាលខេត្ត កំពង់ចាម |
| លោកវេជ្ជ. កប វណ្ណដា | មន្ត្រីបច្ចេកទេសអង្គការសុខភាពពិភពលោកប្រទេសកម្ពុជា |
| លោកឱសថការី តឹក ប៊ុនឈឿង | មន្ត្រីបច្ចេកទេសអង្គការសុខភាពពិភពលោកប្រទេសកម្ពុជា |
| លោកវេជ្ជ. Knut Erik Hovda | Consultant clinical toxicology Oslo university, Norway |
| លោកវេជ្ជ. គឹម ចំរើនសាន្ត | ប្រធានគ្រប់គ្រងវេជ្ជសាស្ត្រ អង្គការគ្រូពេទ្យគ្មានព្រំដែន |
| លោកវេជ្ជ. ហង់ វិច្ឆរនោថ | អង្គការគ្រូពេទ្យគ្មានព្រំដែន |
| លោក ថន មាឃ | ជំនួយការនាយក អង្គការគ្រូពេទ្យគ្មានព្រំដែន |

# ស្ថានភាពនៃការពុលមេតាណុល

## ១.សារបាន/យន្តការនៃភាពពុល




មេតាណុលមិនពុលទេ ប៉ុន្តែវាធ្វើមេតាបូលីសទៅជា អាស៊ីតហ្វូមីក ឬ ហ្វូម៉ាត ដែលពុលខ្លាំង។ ការព្យាបាលគឺផ្តោតលើការរារាំងអង់ហ្ស៊ីម ADH ដោយប្រើថ្នាំបន្សាប [អេតាណុល ឬ ហ្វូមេពីហ្សូល (Fomepizole)] ឬដាក់បន្ថែម ប៊ីកាបូណាតដើម្បីបន្ថយមេតាបូលិកអាស៊ីត (metabolic acidosis) និង ប្រើវិធីលាងឈាមដើម្បីសម្អាតមេតាណុល និងហ្វូម៉ាត ហើយអាចកែសម្រួលមេតាបូលិកអាស៊ីត ។ អាស៊ីតហ្វូមីកកាន់តែច្រើន ធ្វើអោយអ្នកជំងឺពុលកាន់តែខ្លាំង ដោយសារមេតាបូលិកអាស៊ីតកាន់តែធ្ងន់ធ្ងរ ។ ហ្វូលីកអាស៊ីត អាចជួយសម្រួលសារពាង្គកាយពន្លឿនការបំបែកហ្វូម៉ាត។

វិធីសង្គ្រោះទាំងអស់ខាងលើគួរចាប់ផ្តើមភ្លាមៗ។ វិធីព្យាបាលមួយណាក៏សំខាន់ដែរ ប៉ុន្តែ – <u>ប្រើអ្វីដែលមាន!</u>

## ២.រោគវិនិច្ឆ័យ

- **ប្រវត្តិលម្អិតរបស់អ្នកជំងឺ គឺសំខាន់ខ្លាំងណាស់៖ តើបញ្ហានេះអាចជាការពុលមេតាណុលឬទេ?**
  ការផឹក ស្រាដែលគ្មានប្រភពច្បាស់លាស់ ឬ ស្រាដែលលក់ខុសច្បាប់ ឬ មានគ្រួសារ, មិត្តភក្តិដែលមានការសង្ស័យ ឬមានការបញ្ជាក់ច្បាស់ថាពុល សារធាតុមេតាណុល (ឈឺធ្ងន់ធ្ងរ ស្លាប់ ងងឹតភ្នែក ។ល។)

- **រោគសញ្ញាលេចចេញក្នុងអំឡុង ១២-២៤ម៉ោង ក្រោយផឹក ឬ លើស** (ប្រសិនបើរោគសញ្ញា កើតឡើងក្នុងរយៈពេលខ្លីភ្លាមៗ ក្រោយពេលផឹក មិនទំនងជាការពុលសារធាតុមេតាណុលទេ)។

- **រោគសញ្ញា៖ ហត់ ឬ ដង្ហើមញាប់** (ចង្វាក់ដង្ហើម លើស ២០-២៥ដងក្នុងមួយនាទី), ពិបាកដកដង្ហើម, ព្រិលភ្នែក (គ្រប់ប្រភេទ), រោគសញ្ញាក្រពះពោះវៀន (ក្អួតញឹកញាប់ និង ឈឺក្រពះផងដែរ ។ល។), ឈឺទ្រូង, ឈឺក្បាល, ធីងធោងខុសប្រក្រតី (មិនស្រួលក្នុងខ្លួនខ្លាំង រយៈពេល ១-២ ថ្ងៃក្រោយពេលផឹក)។

- **រោគវិនិច្ឆ័យដោយមន្ទីរពិសោធន៍៖** រោគវិនិច្ឆ័យអាចបំពេញបន្ថែមដោយការប្រើ ការវិភាគឧស្ម័នក្នុងឈាម (សូមមើលតារាងទី២ខាងក្រោម) ដោយធ្វើការវិភាគច្បាស់លាស់ ទៅលើសារធាតុពុលរបស់ ហ្វូម៉ាត (សូមមើលតារាងទី ៣ ខាងក្រោម) ឬ ដោយវិភាគរកមេតាណុល (កម្រធ្វើបាន)។

## ៣.ការគ្រប់គ្រងអ្នកជំងឺ

### ៣.១ ករណីគ្មានឧបករណ៍វិភាគឧស្ម័នក្នុងឈាម (Arterial Blood Gas Machine) ដោយផ្អែកលើរោគសញ្ញាគ្លីនិកតែប៉ុណ្ណោះ (សូមមើលតារាងទី ១)

A. **អ្នកជំងឺគ្មានរោគសញ្ញា៖** តាមដានរយៈពេល ២៤ ម៉ោង (អាស្រ័យលើស្ថានភាពរបស់អ្នកជំងឺ)។

B. **ការដកដង្ហើមញាប់, ដោយគ្មានសញ្ញាព្រិលភ្នែក ហើយនៅដឹងខ្លួន ៖** បញ្ចូលសេរ៉ូម ១-២ លីត្រ (ឧ.NaCl 0.៩%) + វិតាមីនបេ១ (Thiamine) (ឧ. ១០០មក្រ ឬ ២៥០មក្រ) + គ្លុយកូស (glucose) (ឧ. ១០០០ មល នៃ ៥០មក្រក្នុងមួយមល (៥%)) ក្នុងរយៈពេល ៣០-៦០ នាទី។ ប្រសិនបើសញ្ញា អាស៊ីដូស បានកែតម្រូវ ឬ ប្រសើរជាងមុន (ដង្ហើមមិនសូវញាប់ ឬលែងហត់) វាទំនងជា alcoholic ឬ diabetic ketoacidosis, ដោយមិនមែនជាការពុលមេតាណុលទេ។
ប្រសិនបើមិនបានធូរស្រាលក្នុងរយៈពេល១ម៉ោងក្រោយមកទេ ៖ ចូរផ្តល់អេតាណុល ឬហ្វូមេពីហ្សុល (Fomepizole) និង ប៊ីកាបូណាត (bicarbonate) រួចបញ្ជូនអ្នកជំងឺទៅកាន់មជ្ឈមណ្ឌលលាងឈាម បើអាចធ្វើទៅបាន។ ត្រូវតាមដានយ៉ាងតិច ២៤ ម៉ោង ក្រោយពេលបញ្ចប់ការព្យាបាល (សូមមើល កម្រិតថ្នាំដែលបានបញ្ជាក់ខាងក្រោម)។

C. **ការដកដង្ហើមញាប់ និងមានសញ្ញាព្រិលភ្នែក ហើយនៅដឹងខ្លួន ៖** ផ្តល់អេតាណុល ឬ ហ្វូមេពីហ្សុល (Fomepizole), ប៊ីកាបូណាត (Bicarbonate) និងអាស៊ីដហ្វូលីក រួចបញ្ជូនអ្នកជំងឺទៅកាន់មជ្ឈមណ្ឌលលាងឈាម បើអាចធ្វើទៅបាន។ ត្រូវតាមដានយ៉ាងតិច ២៤ ម៉ោង ក្រោយពេលបញ្ចប់ការព្យាបាល (សូមមើល កម្រិតថ្នាំដែលបានបញ្ជាក់ខាងក្រោម)។

D. **ការដកដង្ហើមញាប់ ហើយមិនដឹងខ្លួន៖** ផ្តល់អេតាណុល ឬ ហ្វូមេពីហ្សុល (Fomepizole), ប៊ីកាបូណាត (Bicarbonate) និង អាស៊ីតហ្វូលិក រួចត្រូវបញ្ជូនអ្នកជំងឺទៅកាន់មជ្ឈមណ្ឌលលាងឈាម។ ត្រូវតាមដានយ៉ាងតិច ២៤ ម៉ោង ក្រោយពេលបញ្ចប់ការព្យាបាល (សូមមើល "កម្រិតថ្នាំដែលបានបញ្ជាក់ខាងក្រោម")។

E. **មានដង្ហើមធម្មតា ឬយឺត ហើយមិនដឹងខ្លួន ៖** ការព្យាករណ៍ពីស្ថានភាពជំងឺក្នុងករណីនេះ ទំនងជា មិនសូវល្អទេ ប្រសិនបើពុលសារធាតុមេតាណុល។ ត្រូវប្រុងប្រយ័ត្ន ប្រសិនបើករណីនេះគឺជាការពុល អេតាណុលវិញ គឺត្រូវព្យាបាលតាមរោគសញ្ញា។ ត្រូវព្យាបាលតាមការពុលមេតាណុល *ប្រសិនបើសង្ស័យថាពិតជាពុលសារធាតុមេតាណុល។*

### ៣.២ ករណីមានឧបករណ៍វិភាគឧស្ម័នក្នុងឈាម (Arterial Blood Gas Machine) ដោយផ្អែកលើកម្រិតឧស្ម័នក្នុងឈាមរបស់អ្នកជំងឺ (សូមមើលតារាងទី ២)

A. **អ្នកជំងឺដែលគ្មានរោគសញ្ញា ហើយឧស្ម័នក្នុងឈាមធម្មតា៖** តាមដានរយៈពេល ២៤ ម៉ោង (អាស្រ័យលើស្ថានភាពរបស់អ្នកជំងឺ)។

B. **$HCO_3$ >១៥ ឬ BD <១០, pH > ៧.២:** បញ្ចូលសេរ៉ូម ១-២ លីត្រ (ឧ. NaCl 0.៩%) + វិតាមីនបេ១ (Thiamine) (ឧ. ១០០មក្រ ឬ ២៥០មក្រ) + គ្លុយកូស (glucose) (ឧ. ១០០០ មល នៃ ៥០មក្រក្នុងមួយមល (៥%)) ក្នុងរយៈពេល ៦០ នាទី។ ប្រសិនបើសញ្ញាអាស៊ីដូស (acidosis) ត្រូវបានកែតម្រូវ ឬ មានភាពប្រសើរឡើង៖ វាទំនងជា alcoholic ឬ diabetic ketoacidosis, ដោយមិនមែនជាការពុលមេតាណុលទេ។ ប្រសិនបើមិនធូរស្រាលក្នុងរយៈពេល ១ម៉ោងក្រោយមកទេ ចូរផ្តល់អេតាណុល(Ethanol) ឬ ហ្វូមេពីហ្សុល (Fomepizole) និង ប៊ីកាបូណាត (Bicarbonate)។ រួចបញ្ជូនអ្នកជំងឺទៅមជ្ឈមណ្ឌលលាងឈាម បើអាចធ្វើទៅបាន។ ត្រូវតាមដានយ៉ាងតិច ២៤ ម៉ោង បន្ទាប់ពីបញ្ចប់ការព្យាបាល (សូមមើល កម្រិតថ្នាំដែលបានបញ្ជាក់ខាងក្រោម)។

C. **$HCO_3$ ១០-១៥ ឬ BD ១០-១៥, pH ៧.០-៧.២:** បញ្ចូលសេរ៉ូម ១-២ លីត្រ (ឧ. NaCl 0.៩%) + វិតាមីន បេ១ (Thiamine) (ឧ. ១០០មក្រ ឬ ២៥០មក្រ) + គ្លុយកូស (glucose) (ឧ. ១០០០ មល នៃ ៥០មក្រក្នុងមួយមល (៥%)) ក្នុងរយៈពេល ៦០ នាទី។ ប្រសិនបើសញ្ញាអាស៊ីដូស (acidosis) ត្រូវបានកែតម្រូវ ឬ មានភាពប្រសើរឡើង៖ វាទំនងជា alcoholic ឬ diabetic ketoacidosis, ដោយមិនមែនជាការពុលមេតាណុលទេ។ ប្រសិនបើមិនធូរស្រាលក្នុងរយៈពេល ១ម៉ោងក្រោយមកទេ ចូរផ្តល់អេតាណុល (Ethanol) ឬ ហ្វូមេពីហ្សុល (Fomepizole) និង ប៊ីកាបូណាត (Bicarbonate)។ រួចបញ្ជូនអ្នកជំងឺទៅមជ្ឈមណ្ឌលលាងឈាម បើអាចធ្វើទៅបាន។ ត្រូវតាមដានយ៉ាងតិច ២៤ ម៉ោង បន្ទាប់ពីបញ្ចប់ការព្យាបាល (សូមមើល កម្រិតថ្នាំដែលបានបញ្ជាក់ខាងក្រោម)។

D. **$HCO_3$<១០ or BD>១៥, pH <៧.០:** ផ្តល់អេតាណុល ឬ ហ្វូមេពីហ្សុល (Fomepizole), ប៊ីកាបូណាត (Bicarbonate), លាងឈាម, និង អាស៊ីតហ្វូលិក។ ត្រូវតាមដានយ៉ាងតិច ២៤ ម៉ោង បន្ទាប់ពីបញ្ចប់ការព្យាបាល(សូមមើល កម្រិតថ្នាំដែលបានបញ្ជាក់ខាងក្រោម)។

*** ឆាប់ផ្តល់ ប៊ីកាបូណាត (Bicarbonate ) និង អេតាណុល (Ethanol) នៅក្នុងក្រុម C ជាង B ប្រសិនបញ្ហាអាស៊ីដូស (acidosis) ក្នុងឈាមកាន់តែធ្ងន់ធ្ងរ។*

## ៤.ការព្យាបាល៖

A. **ផ្តល់ថ្នាំបន្សាប** (អេតាណុល តាមមាត់ ឬតាមសរសៃវ៉ែន ឬ ហ្វូមេពីហ្សុល (Fomepizole) ភ្លាមៗដោយមិនត្រូវពន្យារពេល។ សម្រាប់កម្រិតថ្នាំ៖ សូមមើលខាងក្រោម

B. **ផ្តល់ប៊ីកាបូណាត** *Bicarbonate* (NaHCO3) តាមសរសៃវ៉ែន កាន់តែលឿនកាន់តែល្អ តាមដែលអាចធ្វើទៅបាន។ សម្រាប់កម្រិតថ្នាំ៖ សូមមើលខាងក្រោម

C. **អាស៊ីតហ្វូលិក** (ឬអាស៊ីតហ្វូលីនិក) ៥០ ម.ក តាមសរសៃវ៉ែន ឬ តាមមាត់ (ឧទា. ១០គ្រាប់ នៃ ៥ម.ក) រៀងរាល់ ៦ ម៉ោងម្តង សម្រាប់រយៈពេល ២៤-៤៨ ម៉ោង។

D. **ការលាងឈាម៖**

a. **ការលាងឈាមជាដំណាក់ៗ** (Intermittent Hemodialysis = ការលាងឈាមលំហូរលឿន ឬ ការលាងឈាមធម្មតា) សម្រាប់រយៈពេល ៦-៨ ម៉ោង ឬ

b. **លាងឈាមជាប់ជាបន្ត** (Continuous Renal Replacement Therapy or Continuous Veno-Venous Hemodialysis or Continuous Veno-Venous Hemodialysis Filtration) សម្រាប់រយៈពេលយ៉ាងតិច ១៨ ម៉ោង។

c. **ប្រសិនបើមិនមានកន្លែងលាងឈាម ៖** ចូរពិចារណាបញ្ជូនអ្នកជំងឺទៅកាន់កន្លែងលាងឈាម។ **ចាប់ផ្តើមប្រើថ្នាំបន្សាប និង ប៊ីកាបូណាត** ***(Bicarbonate)*** ប្រសិនបើចាំបាច់ មុនពេលបញ្ជូន។

d. **ប្រសិនបើមានវិធីលាងស្រោមពោះ ៖** ចូរព្យាបាលរយៈពេលយ៉ាងតិច ៤៨ ម៉ោង (មិនមានឯកសារបញ្ជាក់)

e. **ប្រសិនបើមានម៉ាស៊ីនលាងឈាមមិនគ្រប់គ្រាន់(*ក្នុងករណីអ្នកជំងឺច្រើន*) ៖** ចូរពិចារណាផ្លាស់ប្តូរវេន ក្នុងការលាងឈាម។ ដោយអ្នកជំងឺម្នាក់ត្រូវលាងពី ១-២ ម៉ោងដើម្បីជានាជីវិត រួចបន្តអ្នកជំងឺ ផ្សេងទៀត។ បន្ទាប់មក ប្តូរមួយជុំថ្មីទៀត។

E. **ប្រសិនបើចាំបាច់ត្រូវដាក់ទុយោដង្ហើម (Intubation) ៖** ត្រូវអោយអ្នកជំងឺមានចំនួនចង្វាក់ដង្ហើមញាប់ (RF >២៥ដងក្នុងមួយនាទី) រហូតដល់ metabolic acidosis ត្រូវបានកែតម្រូវ។

## ការព្យាករណ៍ពីស្ថានភាពអ្នកជំងឺ

បើអ្នកជំងឺពុលដោយសារជាតុមេតាណុល មកដល់មន្ទីរពេទ្យក្នុងស្ថានភាពសន្លប់ (coma) ឬ មានភាពធ្ងន់ធ្ងរនៃមេតាបូលិកអាស៊ីត (pH <៦.៩-៧.0 និង HCO3 <១០ ឬ base deficit>២០) និង ចំនួនចង្វាក់ដង្ហើមយឺត មានន័យថាការព្យាករណ៍ស្ថានភាពអ្នកជំងឺមិនល្អទេ។ ប៉ុន្តែបើអ្នកជំងឺមានការពុលអេតាណុលតែមួយមុខ ឬ ពុលសារជាតុទាំងពីរមុខ ការព្យាករណ៍ពីស្ថានភាពជំងឺគឺអាចខុសពីនេះ។

## តារាងទី ១ ៖ ដំណើរការធ្វើរោគវិនិច្ឆ័យនៅពេលគ្មានឧបករណ៍វិភាគឧស្ម័នក្នុងឈាម (Arterial Blood Gas Machine)




1 ជានិច្ចជាកាលត្រូវគិតពីមូលហេតុផ្សេងទៀតដែលបង្កអោយមានមេតាបូលិកអាស៊ីត៖

- *Diabetes ketoacidosis :* ដឹងថាមានជំងឺទឹកនោមផ្អែម? ត្រូវធ្វើតេស្តជាតិស្ករក្នុងឈាម
- ***ខ្សោយតម្រងនោម:*** ដឹងថាមានជំងឺខ្សោយតម្រងនោម? បរិមាណទឹកនោម? Creatinine?
- ***ការបង្ករោគក្នុងឈាម*** *:* តើមានសញ្ញាបង្ករោគឬទេ? ក្តៅខ្លួន? គោលិកាឈាមស? CRP? ។ល។

## តារាងទី ២៖ ដំណើរការធ្វើរោគវិនិច្ឆ័យនៅពេលមានឧបករណ៍វិភាគឧស្ម័នក្នុងឈាម (Arterial Blood Gas Machine)




1 ជានិច្ចជាកាលត្រូវគិតពីមូលហេតុផ្សេងទៀតដែលបង្កអោយមានមេតាបូលិកអាស៊ីត៖

- *Diabetes ketoacidosis :* ដឹងថាមានជំងឺទឹកនោមផ្អែម? ត្រូវធ្វើតេស្តជាតិស្ករក្នុងឈាម
- ***ខ្សោយតម្រងនោម:*** ដឹងថាមានជំងឺខ្សោយតម្រងនោម? បរិមាណទឹកនោម? Creatinine?
- ***ការបង្ករោគក្នុងឈាម :*** តើមានសញ្ញាបង្ករោគឬទេ? ក្តៅខ្លួន? គោលិកាឈាមស? CRP? ។ល។

2 ជានិច្ចជាកាល pH អាស្រ័យលើ កំរិតដង្ហើមញាប់ ដូច្នេះត្រូវផ្តោតជាដំបូងទៅលើ BD និង HCO3

## តារាងទី ៣: ការធ្វើតេស្តរកហ្វូម៉ាត (formate assay) (ប្រសិនបើមាន)




យកចេញពី៖ *Hovda KE, McMartin KE, Jacobsen D. Methanol and formaldehyde poisoning. In: Brent J, Megarbane B, Palmer R, Hatten B, Burkhart K (eds). Critical Care Toxicology, 2nd Edition. Springer Publishing, New York. 2017. 1769-86.*

# ការព្យាបាល - កម្រិតប្រើប្រាស់ថ្នាំ៖

- ថ្នាំបន្សាប
  ការព្យាបាលដោយថ្នាំបន្សាប គួរតែមានរយៈពេល ៥ ទៅ ៧ ថ្ងៃ ប្រសិនបើមិនមានការលាងឈាម។ តាមដាន និងវាយតម្លៃឡើងវិញ រយៈពេល ២៤ ម៉ោង ក្រោយពេលព្យាបាលត្រូវបានបញ្ចប់ ដើម្បីឱ្យប្រាកដថាគ្មាន ការកើតឡើងអាស៊ីដូសក្នុងឈាម។

- អេតាណុល (ត្រូវដឹងពីភាពខុសគ្នាពីកម្រិតប្រើប្រាស់ថ្នាំរវាងបុគ្គលម្នាក់ៗ)។
  **កម្រិតប្រើ តាមមាត់ = កម្រិតប្រើតាមសរសៃវ៉ែន**
  លក្ខណៈទូទៅ៖ ស្រាបៀរមានជាតិអេតាណុល ៥%, ស្រាទំពាំងបាយជូ ១២-១៤% និងវិស្គី ៤០-៤៥% ។ កម្រិតភាគរយខ្ពស់ជាងនេះក៏អាចប្រើបាន។

| | 5% អេតាណុល | 10% អេតាណុល | 20% អេតាណុល | 40% អេតាណុល |
|---|---|---|---|---|
| **កម្រិតដំបូង** | 15mL/kg | 7.5mL/kg | 4mL/kg | 2mL/kg |
| **ផ្តល់អោយចំពោះអ្នក** ផឹកមិនប្រចាំ | 2mL/kg/hr | 1mL/kg/hr | 0.5mL/kg/hr | 0.25mL/kg/hr |
| **ផ្តល់អោយចំពោះអ្នក** ផឹកប្រចាំ | 4mL/kg/hr | 2mL/kg/hr | 1mL/kg/hr | 0.5mL/kg/hr |
| **ផ្តល់អោយចំពោះអ្នក** ផឹកមិនប្រចាំ ករណីលាងឈាម | 4mL/kg/hr | 2mL/kg/hr | 1mL/kg/hr | 0.5mL/kg/hr |
| **ផ្តល់អោយចំពោះអ្នក** ផឹកប្រចាំ ករណីលាងឈាម | 6mL/kg/hr | 3mL/kg/hr | 1.5mL/kg/hr | 0.8mL/kg/hr |

- *Fomepizole (ប្រសិនបើមាន):*
  - ឱ្យ ១៥mg/kg ជាកម្រិតដំបូង បន្ទាប់មក ឱ្យ ១0mg/kg រៀងរាល់ ១២ ម៉ោង។ រួចបង្កើនកម្រិតដល់ ១៥mg/kg ក្រោយឱ្យកម្រិតលើកទី ៥ រួច ។ អំឡុងពេលលាងឈាម៖
    - IHD: ឱ្យរៀងរាល់ ៤ ម៉ោងម្តង។
    - CRRT: ឱ្យរៀងរាល់ ៨ ម៉ោងម្តង។
  - បើមាន fomepizole តិចតួច ចូរព្យាបាលសម្រាប់រយៈពេល ២៤ ម៉ោង (ពីរ ឬបីដូសច្រើនបំផុតសម្រាប់អ្នកជំងឺម្នាក់) បន្ទាប់មក បន្តឱ្យអេតាណុលនៅ ២៤ ម៉ោងក្រោយ។

- **ប៊ីកាបូណាត (Bicarbonate)**
  - គណនាតម្រូវការផ្តល់ឱ្យ ផ្អែកលើឧបករណ៍វិភាគឧស្ម័នក្នុងឈាម (ABG)៖
    0.៣ x ទម្ងន់អ្នកជំងឺ (kg) x Base deficit = mmol HCO3
    ឧ. អ្នកជំងឺទម្ងន់ ៧0kg, BD ៣0 mmol/L: 0.៣ x ៧0 x ៣0 = ៦៣0 mmol HCO3

- ប្រសិនបើគ្មាន ឧបករណ៍វិភាគឧស្ម័នក្នុងឈាម (ABG):

a. **១000 mmol/L (Cambodia):** ឱ្យ ៧-១៥ អំពូល ចំណុះ២0mLក្នុងមួយអំពូល នៃ $NaHCO_3$ ៨.៤% ឬច្រើនជាងនេះ ក្នុងរយៈពេល ១-២ ម៉ោង រហូតដល់ដង្ហើមញាប់ត្រូវបានកែតម្រូវ (RF <២0ដង / នាទី)។

b. **៥00 mmol/L:** ឱ្យ ២៥0-៥00mL ឬច្រើនជាងនេះ ក្នុងរយៈពេល ១-២ ម៉ោង រហូតដល់ដង្ហើមញាប់ត្រូវបានកែតម្រូវ (RF <២0ដង /នាទី)។

c. **១៦៧ mmol/L**: Give ១000-១៥00mL ឬច្រើនជាងនេះ ក្នុងរយៈពេល ១-២ ម៉ោង រហូតដល់ដង្ហើមញាប់ត្រូវបានកែតម្រូវ (RF <២0ដង /នាទី)។
ប្រសិនបើមានតែការព្យាបាលតាមមាត់៖ ឱ្យថ្នាំគ្រាប់ប៊ីកាបូណាត ៥00 mg (= ៦ mmol), ៦-១0 គ្រាប់ រៀងរាល់ម៉ោង រហូតដល់ដង្ហើមញាប់ត្រូវបានកែតម្រូវ (RF <២0ដង/នាទី)។

- **អាស៊ីតហ្វូលិក** (ឬអាស៊ីតហ្វូលីនិក) ៥0មក្រ តាមសរសៃវ៉ែន ឬតាមមាត់ (ឧ. ១0 គ្រាប់ ៥មក្រ) រៀងរាល់ ៦ ម៉ោង សម្រាប់រយៈពេល ២៤-៤៨ ម៉ោង។

**តើត្រូវហៅរកជំនួយនៅពេលណា៖**
ប្រសិនបើមានអ្នកជំងឺដែលសង្ស័យថាពុលសារធាតុមេតាណុល ចូរទូរស័ព្ទទៅកាន់ក្រុមឆ្លើយបន្ទាន់ថ្នាក់ខេត្ត ឬ មន្ទីរពេទ្យក្នុងមូលដ្ឋានរបស់អ្នក ឬ ទូរស័ព្ទទាន់ហេតុការណ៍ ១១៥ ដើម្បីសុំយោបល់ និងពិភាក្សាអំពីលទ្ធភាពអន្តរាគមន៍។

មូលហេតុសំខាន់នៃការធ្វើបែបនេះ គឺដើម្បីមានលទ្ធភាពកំណត់អំពីការពុលជាតិអាល់កុលនៅក្នុងសហគមន៍ និង ចាប់ផ្តើមការព្យាបាលឱ្យបានឆាប់ **ព្រមទាំងប្រកាសព័ត៌មានដល់សាធារណជនអំពីគ្រោះថ្នាក់ដែលអាចកើតមាន។**

**នៅទីណាដែលមានមួយករណី ជាធម្មតាគឺមានច្រើនករណីផ្សេងទៀតដែរ។**